00158319

Declassified to Public
06 September 2012

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 01 / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

A 56

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

***

ខ្ញុំបាទឈ្មោះ **ការ សាវុត្ថ** (KAR SAVUTH) អត្តលេខ ០០៥ មានការិយាល័យផ្ទះលេខ ១០៤ $E_2$ មហាវិថី សុធារស សង្កាត់ ចតុមុខ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១២ ៨៩៥ ៥១៩ និងលេខ ០១៦ ៨២៣ ៥៨១ ជាមេធាវីការពារអោយជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ។

**សូមគោរពជូនមក**

**លោក យូ ប៊ុនឡេង និង លោក Marcel Lemonde**

**សហចៅក្រមស៊ើបអង្កេត**

**<u>សូមមេត្តាជ្រាប</u>** ។

**<u>កម្មវត្ថុ:</u>** សូមមេត្តាចេញសេចក្តីសម្រេចទទួលស្គាល់សហមេធាវី-ទីប្រឹក្សាច្បាប់ និងជំនួយការសារជាថ្មី ។

**<u>យោង:</u>** លិខិតលេខ ០០/០៨ ម.ឃ.ស.ក ចុះថ្ងៃទី០៨-០១-២០០៨របស់មន្ទីរឃុំឃាំង ។

តបតាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមអនុញ្ញាតជំរាបជូនលោកសហចៅក្រមស៊ើបអង្កេតមេត្តាជ្រាបថា: មន្ទីរឃុំឃាំងបណ្តោះអាសន្ននៃ អ.វ.ត.ក បានជូនដំណឹងមកយើងខ្ញុំជាសហមេធាវីការពារជនត្រូវចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ថា សុពលភាពនៃការទទួលស្គាល់ជាសហមេធាវីជនត្រូវចោទនោះ ត្រូវផុតកាលបរិច្ឆេទទៅហើយ ដែលតម្រូវអោយសហមេធាវីមានសេចក្តីសម្រេចទទួលស្គាល់ជាថ្មីពីសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ។

អាស្រ័យហេតុនេះ សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាជួយចេញសេចក្តីសម្រេចទទួលស្គាល់យើងខ្ញុំ **ការ សាវុត្ថ** និង Francois Roux ជាសហមេធាវី ព្រមទាំងទីប្រឹក្សាច្បាប់ និង ជំនួយការសារជាថ្មី ។

សូមលោកសហចៅក្រមស៊ើបអង្កេតទាំងពីរមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

ធ្វើនៅភ្នំពេញ,ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៨

សំរាប់សហមេធាវីទាំងពីរ

មេធាវីម្នាក់ក្នុងចំណោមសហមេធាវីទាំងពីរ

មេធាវី **ការ សាវុត្ថ**